# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០.២២...សហវ

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបង្ហាញខ្លួនរបស់បេក្ខជនទាំងពីរភេទ ក្របខ័ណ្ឌ "ក" ដែលបានប្រឡងជាប់ជាស្ថាពរ ចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់បេក្ខជនទាំងពីរភេទ ក្របខ័ណ្ឌ "ក" ដែលបានប្រឡងជាប់ជាស្ថាពរដើម្បីចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នាសម័យប្រឡងថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៦ នៅមណ្ឌលប្រឡងសាកលវិទ្យាល័យភូមិន្ទភ្នំពេញឱ្យជ្រាបថា បេក្ខជនទាំងពីរភេទត្រូវមកបង្ហាញខ្លួន និង បំពេញសំណុំបែបបទចូលបម្រើការងារចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៦ រៀងរាល់ថ្ងៃនៅក្នុងម៉ោងធ្វើការ÷

- ពេលព្រឹក: ម៉ោង ០៧.០០ ដល់ម៉ោង ១១.៣០
- ពេលរសៀល: ម៉ោង ១៤.០០ ដល់ម៉ោង ១៧.៣០
- ទីកន្លែង: *សាលាជាតិពន្ធដារ ជាន់ទី៨ អាសយដ្ឋាន អគារលេខ ៤១-៤៣ ផ្លូវលេខ ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។*

ក្នុងករណី បេក្ខជនខកខានមិនបានមកបង្ហាញខ្លួនតាមកាលកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចាត់ទុកថា បេក្ខជនបោះបង់ចោលការងារ និងត្រូវបានលុបឈ្មោះចេញដោយស្វ័យប្រវត្តិ ។ បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរ និង ជាប់បម្រុង អាចទៅពិនិត្យបញ្ជីឈ្មោះ ដែលមានបិទផ្សាយនៅ*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាលាជាតិពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ និង នៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ឬបេក្ខជនអាចទទួលព័ត៌មានពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh, គេហទំព័ររបស់នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិញ្ញវត្ថុ www.pd.mef.gov.kh ឬ គេហទំព័ររបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ www.efi.mef.gov.khចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៦ ។

អាស្រ័យនេះ សូមបេក្ខជនទាំងពីរភេទដែលបានប្រឡងជាប់ជាស្ថាពរចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ មកបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលបានកំណត់ខាងលើកុំបីខាន ។

**រដ្ឋលេខាធិការ**

**ប្រធានគណៈកម្មការប្រឡង**

**បណ្ឌិត ហ៊ាន សាហ៊ីប**

Collection by VCAT Professional Consultant

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798